# របាយការណ៍អំពីកិច្ចការត្រូវបានធ្វើក្នុងគ្រា កូវីដ-១៩ (COVID-19)

| ឈ្មោះក្រសួងអប់រំប្រចាំតំបន់ (អ៊ិលអ៊ីអេ) | ឈ្មោះសំរាប់ទាក់ទង និង មុខងារ | អ៊ីម៉េល និង លេខទូរស័ព្ទ | ថ្ងៃ ខែ នៃការរៀបចំបង្កើត |
|---|---|---|---|
| Long Beach Unified School District (LBUSD) | Christopher J. Steinhauser, អគ្គនាយកសាលារៀន | CSteinhauser@lbschools.net<br>562-997-8242 | ថ្ងៃទី2 ខែមិថុនា 2020 |

**សេចក្តីរៀបរាប់ ដែលបានលើកបង្ហាញ គឺគួររាប់បញ្ចូលផងទាំងកិច្ចការយ៉ាងគ្រប់គ្រាន់ផ្សេងៗសំរាប់បញ្ជាក់អំពីការយល់ដឹងកាន់តែជ្រៅនៃភាពកែប្រែទាំងឡាយណា ដែលក្រសួង អ៊ិលអ៊ីអេ របស់អ្នកបានចាត់ចែងធ្វើមក ។ ក្រសួង អ៊ិលអ៊ីអេ គួរលើកបង្ហាញជាសេចក្តីរៀបរាប់អោយបានក្បោះក្បាយ ដោយមិនប្រើលើសពីចំនួន 300 ពាក្យ ។**

លើកបង្ហាញសេចក្តីសង្ខេបនៃការពន្យល់ភាពកែប្រែមកលើកម្មវិធី ដែលក្រសួង អ៊ិលអ៊ីអេ បានចាត់ចែងដោះស្រាយ នៅពេលសាលារៀនកំពុងតែបិទ ដោយមូលហេតុភាពអាសន្ន កូវីដ-១៩ និង មកលើបញ្ហាធ្ងន់ធ្ងរផ្សេងៗទាក់ទងការបិទសាលារៀន ដែលនាំប៉ះពាល់ទៅកាន់សិស្ស និង ក្រុមគ្រួសារ ។

ក្រសួងអប់រំ ឌីស្រ្ទីគ ឡុង ប៊ីច (Long Beach Unified School District – LBUSD) ប្រឹងប្រែងសព្វយ៉ាងសំរាប់ការពារសុខភាព និង រក្សាភាពសន្តិសុខទៅកាន់សិស្ស ក្រុមគ្រួសារ និង បុគ្គលិកទូទៅ ។ នៅពេលភាពអាសន្ន កូវីដ-១៩ បានចាប់ផ្តើមភ្លាម ក្រសួងអប់រំ LBUSD ក៏បានធ្វើសហការជាមួយក្រសួងសុខាភិបាល និង ក្រសួងផ្សេងៗទៀត តាមរបៀបប្រយ័ត្នប្រយែង ដើម្បីជួយបន្ថយការចម្លងមេរោគ ដោយនៅពេលជាមួយគ្នានោះដែរ គឺស្វែងរកមធ្យោបាយសំរាប់ដោះស្រាយជូនក្រុមរួមចំណែកទាំងអស់ ។

នៅថ្ងៃទី12 ខែមិនា 2020 គឺកិច្ចការមិនចាំបាច់ទាំងប៉ុន្មាន ដែលតំរូវការចូលរួមពីមនុស្សជាច្រើននាក់ ដូចជាៈ កិច្ចប្រជុំក្នុងសាលារៀន កម្មវិធីហ្វឹកហ្វឺនសំរាប់បុគ្គលិក និង កម្មវិធីផ្សេងៗនៅតាមសហគមន៍ ជាដើម ត្រូវបានផ្អាកចោល ។ បួនថ្ងៃបន្ទាប់មក សាលារៀនក៏បានបិទទ្វារ ហើយក្រសួងអប់រំ LBUSD ចាប់ផ្តើមចែកផ្តល់អាហារ និង មេរៀនសំរាប់ហាត់ធ្វើនៅតាមផ្ទះទៅកាន់សិស្ស ។ សាលារៀនទាំងអស់ លើកលែងតែ CAMS ដែលស្ថិតនៅមហាវិទ្យាល័យ California State University Dominguez Hills បានចែកផ្តល់អាហារពេលព្រឹក ពីម៉ោង 8:00–9:00 និង អាហារពេលថ្ងៃត្រង់ ពីម៉ោង 11:30–1:00 រសៀល ទៅកាន់សិស្ស ។ សិស្សអាចទៅទទួលយកអាហារនៅតាមសាលារៀនមួយណាក៏បាន ដោយមិនបាច់បង្ហាញក្រដាសត្រឹមត្រូវ ដោយមូលហេតុពួកគេកំពុងឆ្លងកាត់បញ្ហាលំបាកដ៏ធំមួយរួចមកហើយ ។ ដូច្នេះ យើងមិនចង់នាំការរំខានដល់ពួកគេជាបន្ថែមទៀតទេ ។ សូម្បីតែមានការកែប្រែអំពីកន្លែងចែកផ្តល់អាហារមែនក៏ដោយ បន្ទាប់ពីមួយសប្តាហ៍កន្លងផុតមក ក៏របៀបប្រើចែកផ្តល់នៅតាមសាលារៀន គឺគ្មានអ្វីគួរអោយពិបាកស្មុគស្មាញនោះទេ ។

នៅថ្ងៃទី23 ខែមិនា 2020 ក្រសួងអប់រំ LBUSD បានបង្កើតជា កម្មវិធីរៀននៅតាមផ្ទះ ហៅ Home Learning Opportunities សំរាប់ជួយសិស្សរៀនក្រៅថ្នាក់ ។ មេរៀនត្រូវបានរៀបចំឡើងសំរាប់ជួយសិស្សរៀនក្នុងកម្មវិធីធម្មតា និង កម្មវិធីអប់រំពិសេស ដែលមានដូចជាៈ តំរូកិច្ចការសំរាប់រៀនធ្វើតាមប្រចាំថ្ងៃ បណ្តាញសំរាប់ធ្វើការទាក់ទងជាមួយ និង Google Classroom អំពីគ្រូបង្រៀននិមួយៗ ។ មកដល់ថ្ងៃទី14 ខែឧសភា 2020 យើងបានចំណាំឃើញថា មានអ្នកបើកប្រើតាមជាងចំនួន 60,000 នាក់ និង ក្បែរចំនួន 240,000 នាក់ ដែលបានបើកចូលមើល ។ ចំណែក ដែលបានបើកចូលមើលច្រើនជាងគេ គឺនៅតាមកំរិតថ្នាក់សាលាបឋមសិក្សា កម្មវិធីអប់រំពិសេស K-8 និង ទំព័រសំរាប់មាតាបិតាស្វែងរកជំនួយ ។ ចំពោះសិស្ស ដែលគ្មានមធ្យោបាយប្រើ អ៊ិនធ័រណែត គឺក្រសួងអប់រំ LBUSD បានចែកផ្តល់ជាក្រដាសមេរៀន និង Chromebooks រួមទាំងឧបករណ៍ Wi-Fi hotspot (សូមអានបន្ថែមនៅតាមទំព័រជាបន្តទៅ) ។ បុគ្គលិកប្រចាំការិយាល័យ Parent University បានបំពេញកិច្ចការជាមួយអ្នកជំនាញផ្នែកបច្ចេកវិជ្ជាមកពីក្រសួងផ្សេងៗសំរាប់ផ្តល់ជំនួយទៅកាន់ក្រុមគ្រួសារតាមរយៈទាក់ទងទូរស័ព្ទ និង ការចាក់បង្ហាញភ្លាមៗអំពីកម្មវិធីលើកពន្យល់ក្នុង Youtube ជាភាសា អង់គ្លេស អេស្ប៉ាញ៉ុល និង ខ្មែរ ។ ជំនួយនេះបើកផ្តល់ជូនជាបន្តបន្ទាប់ក្នុងគ្រាកំពុងឆ្លងកាត់ភាពអាសន្ន ។

ចំណុចផ្តើមនៃកម្មវិធីរៀននៅតាមផ្ទះនេះ គឺគ្មានការដាក់ពិន្ទុទៅកាន់សិស្សទេ ហើយបានធ្វើបន្តរហូតដល់សប្តាហ៍សំរាកសំរាប់រដូវផ្ការីក ។ ចាប់ផ្តើមនៅ ថ្ងៃទី23 ខែមេសា 2020 ក្រសួងអប់រំ LBUSD បានបង្កើតមធ្យោបាយថ្មីសំរាប់ដាក់តំរូវអោយសិស្សប្រឹងប្រែងរៀនជាមួយតាមរយៈទទួលពិន្ទុ ដោយមិនធ្វើជ្រុលពេកទេ ជាពិសេសៈ

**ពិន្ទុសំរាប់**

- សិស្សរៀននៅតាមសាលាបឋមសិក្សានឹងមិនត្រូវបានទទួលក្រដាស Achievement Reports ឬ Report Cards នោះទេសំរាប់ ឆមាស លើកទីពីរ ។

- សិស្សរៀនថ្នាក់ទី6 ទៅ ទី8 នឹងបានទទួលពិន្ទុផ្កាច់ព្រ័ត្រជា Pass/Fail ។

- សិស្សរៀនថ្នាក់ទី9 ទៅ ទី12 នឹងបានទទួលពិន្ទុផ្កាច់ព្រ័ត្រជា Credit/No Credit ។

**មធ្យោបាយប្រើតាមជារៀងរាល់ថ្ងៃសំរាប់កម្មវិធីរៀននៅតាមផ្ទះ:**

- សំរាប់ថ្នាក់ Transitional Kindergarten (TK) ទៅ Kindergarten (K): ចំណាយពេលរៀន 1 ទៅ 1.5 ម៉ោងក្នុងមួយថ្ងៃ

- សំរាប់ថ្នាក់ទី1 ទៅ ទី5: ចំណាយពេលរៀន 3 ម៉ោងក្នុងមួយថ្ងៃ

- សំរាប់ថ្នាក់ទី6 ទៅ ទី12: ចំណាយពេលរៀន 3 ទៅ 4 ម៉ោងក្នុងមួយថ្ងៃ

ក្រសួងអប់រំ LBUSD ក៏បានរៀបចំកម្មវិធីរៀនពីចម្ងាយផងដែរតាមរយៈបង្ហាត់មេរៀនភ្លាមៗផ្ទាល់ដោយគ្រូបង្រៀន និង ឬ ដាក់មេរៀនសំរាប់អោយសិស្សម្នាក់ៗហាត់ធ្វើតាមខុសពេលដោយឡែកពីគ្នា ។ នេះជាមធ្យោបាយដែលនឹងប្រើតាមរហូតទាល់តែដល់ពេលចុងបញ្ចប់ឆ្នាំសិក្សា ។

ដោយមូលហេតុថា យើងកំពុងឆ្លងកាត់គ្រាមួយដ៏សែនលំបាក គឺវាពិបាកស្ទង់វាស់ណាស់អំពីចំនួនសិស្ស ដែលចំណាយពេលរៀននៅតាមផ្ទះ សូម្បីតែក្រសួងអប់រំ ឌីស្រ្ទីគ បានបង្ហាញភាពលូតលាស់នៅតាមចំណែកនេះមែនក៏ដោយ ។ ក្នុងចន្លោះពេលសាលារៀនបិទទ្វារ មកដល់ថ្ងៃទី1 ខែឧសភា 2020 គឺមានចំនួនប្រហែល 79% នៃសិស្សបានបញ្ជាក់អោយដឹងថា ពួកគេបានធ្វើការទាក់ទងជាមួយគ្រូរបស់ពួកគេ ហើយមានចំនួនប្រហែល ពីរ ភាគបី បានបញ្ជាក់អោយដឹងថា ពួកគេនៅតែធ្វើការទាក់ទងជាមួយគ្រូដែលមកទល់ក្នុងសប្តាហ៍នៃថ្ងៃទី11 ខែឧសភា 2020 ។ ក្រសួងអប់រំ LBUSD បានប្រើលទ្ធផលនេះ និង លទ្ធផលមកពីកន្លែងផ្សេងៗសំរាប់បង្កើនកម្មវិធីរៀននៅតាមផ្ទះ ។ បន្ថែម ក្រសួងអប់រំបានធ្វើការធ្វើសេចក្តីស្ទង់វាស់មួយទៅកាន់សិស្ស មាតាបិតា និង គ្រូបង្រៀនជាភាសាច្រើនចំណែក ដោយសុំសួរអំពី ... បទពិសោធរបស់ពួកគេនៅពេលបើកប្រើបច្ចេកវិជ្ជា ទំនាក់ទំនងរវាងគ្នាតាមរយៈ អនឡាញ បញ្ហា ដែលពួកគេកំពុងតែទទួល ចំណង់ចិត្ត ដែលពួកគេចង់រៀនបន្តតាមរយៈរៀនពីចម្ងាយនៅតាមផ្ទះ និង ចំណុចសំខាន់ផ្សេងៗទៀត ។ លទ្ធផលបានទទួលមកវិញ គឺសំខាន់សំរាប់ប្រើមកលើការរៀបចំគំរោងទៅថ្ងៃមុខ ។

លើកបង្ហាញសេចក្តីរៀបរាប់នៃជំហាន ដែលបានចាត់ចែងដោយក្រសួង អ៊ិលអ៊ីអេ សំរាប់ផ្តល់ជាជំនួយទៅកាន់សេចក្តីត្រូវការរបស់សិស្សរៀនភាសា អង់គ្លេស សិស្សគេជ្រើសចិញ្ចឹម និង សិស្សមានភាពក្រីក្រ ។

ក្រសួងអប់រំ LBUSD ទទួលស្គាល់ថា គ្រាឆ្លងកាត់ កូវីដ-១៩ នាំមកបញ្ហាធ្ងន់ធ្ងរសំរាប់សិស្ស ជាពិសេស ចំពោះសិស្ស ដែលនៅរៀនខ្សោយជាងគេ ។ ម្លោះហើយ មានមធ្យោបាយថ្មីត្រូវបានរៀបចំប្រើសំរាប់ជួយទៅកាន់ពួកគេក្នុងគ្រាដ៏សែនលំបាកនេះ ។

ជាបឋម ជំនួយផ្នែក បច្ចេកវិជ្ជា ត្រូវបានចែកផ្តល់សំរាប់សិស្សទទួលឱកាសប្រើ អ៊ិនធ័រណែត ដើម្បីបំពេញមេរៀននៅតាមផ្ទះ ។ តាំងពីថ្ងៃទី25 ខែមិនា 2020 កន្លងមក ក្រសួងអប់រំ LBUSD បានចែកផ្តល់ជា Chromebooks ទៅកាន់ក្រុមគ្រួសារ ដោយសុំអោយពួកគេបង្ហាញជារូបថត ID និង លេខ ID របស់សិស្ស ។ នៅ បី ថ្ងៃដំបូង គឺការចែកផ្តល់បានធ្វើទៅពីម៉ោង 8:00–11:00 ព្រឹក នៅតាមសាលារៀនធំជាងគេទាំង ប្រាំ កន្លែង ក្នុងក្រសួងអប់រំ ឌីស្រ្ទីគ ដោយរៀបជាគោលដៅមុនគេសំរាប់ជួយទៅកាន់ក្រុមគ្រួសារទាំងឡាយណា ដែលមានការខ្វះខាតច្រើន ។ មាតាបិតាក៏មានឱកាសផងដែរសំរាប់ណាត់ជួបសាលារៀន ដើម្បីខ្ចី ថាប្លិត យកទៅប្រើនៅតាមផ្ទះ ។ បន្ថែម ឧបករណ៍ Wi-Fi hotspot គឺមានសំរាប់ចែកផ្តល់ ហើយក្រសួងអប់រំ LBUSD បានធ្វើការជាមួយអង្គការមិនយកកំរៃ ហៅ human-I-T ដើម្បីសុំបន្ទុះតំលៃបង់ត្រឹមតែ $15 ក្នុងមួយខែសំរាប់ប្រើ អ៊ិនធ័រណែត តាមរយៈពេលយ៉ាងលឿន និង មិនចាំបាច់ចុះ កុងត្រា ។ មកទល់ថ្ងៃទី7 ខែឧសភា គឺមានចំនួន Chromebooks ជាង 13,000 គ្រឿង និង ឧបករណ៍ hotspot ជាង 1,000 គ្រឿង ត្រូវបានចែកផ្តល់ជូនក្រុមគ្រួសារ ។ នេះរាប់បន្ថែមទាំង ថាប្លិត ចំនួន 20,000 គ្រឿងទៀត ដែលសិស្សអាចទុកប្រើបាននៅតាមផ្ទះតាំងពីពេលផ្តើមចូលរៀនមកម្លេះ ។

ក្រៅតែអំពីការចែកប្រើ បច្ចេកវិជ្ជា ក៏ក្រសួងអប់រំ LBUSD បានធ្វើការទាក់ទងផងដែរទៅកាន់ក្រុមគ្រួសារ ។ ឧទាហរណ៍ៈ បុគ្គលិកប្រចាំក្រសួងអប់រំ ឌីស្រ្ទីគ បានធ្វើការទាក់ទងទៅកាន់ជាង 600 ក្រុមគ្រួសារ ដែលមានឈ្មោះរៀនក្នុងកម្មវិធី Migrant Education និង ទើបមានសិស្សមករៀនក្នុងសហរដ្ឋ ហើយជាសិស្សមិនចេះភាសា អង់គ្លេស ស្ទាត់ ដើម្បីចង់ដឹងអំពីសេចក្តីត្រូវការរបស់ពួកគេ ។ ទំនាក់ទំនងនេះហើយ ដែលបណ្តាលអោយមានការចែកផ្តល់ជា Chromebooks និង hotspot ដែលនៅក្នុងនោះ គឺមានជំនួយបង្ហាញរបៀបបើកប្រើអំពី Google Classroom, Google Meet មេរៀនសំរាប់ហាត់បំពេញតាម រួមទាំងប្រដាប់ប្រើប្រាស់ផ្សេងៗសំរាប់ប្រើបំពេញមេរៀន ។

ជំនួយទាំងអស់នេះបានជួយសិស្សរៀនអំពី Rosetta Stone, Think Central, Khan Academy ជាភាសា អេស្ប៉ាញ៉ុល, iLit និង មេរៀនផ្សេងទៀតតាមរយៈ អនឡាញ សំរាប់ជួយសិស្សរៀនភាសា អង់គ្លេស ។ បើជជែកអំពីផ្នែកបង្ហាត់មេរៀនវិញ គឺមានការិយាល័យ OCIPD បានរៀបចំជាកម្មវិធីហ្វឹកហ្វឺនតាមរយៈ អនឡាញ ការសុំពិគ្រោះ កម្មវិធីបង្ហាប់មេរៀនអំពីរបៀបបង្ហាត់ភាសា អង់គ្លេស និង ការប្រើមធ្យោបាយផ្សេងៗ ដើម្បីជួយទៅកាន់សិស្សមកពីក្រុមពិសេសនេះ ។

បន្ថែម មណ្ឌលផ្តល់ជំនួយសំរាប់ក្រុមគ្រួសារ ហៅ Family Resource Centers ដែលធ្វើការជួយសាលារៀន 26 កន្លែងនៅតាមតំបន់ខ្វះខាតជាងគេក្នុងសហគមន៍ នៅតែបន្តការបើកទ្វារក្នុងម៉ោងធម្មតាសំរាប់ផ្តល់ជំនួយផ្នែកអប់រំផ្លូវចិត្ត និង អារម្មណ៍ទៅកាន់សិស្ស ។ ក្នុងការបំពេញសហការជាមួយ social worker នៃសិស្សគេជ្រើសចិញ្ចឹម គឺបុគ្គលិកមកពីមណ្ឌល FRC បានធ្វើការទាក់ទងទៅកាន់ក្រុមគ្រួសារអំពីជំនួយខ្វះខាត ដូចជាៈ សំលៀកបំពាក់ អាហារ និង កម្មវិធីរៀន រួមទាំងជំនួយអប់រំផ្នែកផ្លូវចិត្ត និង អារម្មណ៍ទៀតផង ។ ពួកគេក៏បានធ្វើការផងដែរជារាល់លើកជាមួយក្រសួង Los Angeles County Department of Children and Family Services ដើម្បីបញ្ជាក់ថា បញ្ហា ពិតជាបានរាយប្រាប់គ្នាទៅវិញទៅមកមែន ។ ស្រដៀងគ្នានេះដែរ បុគ្គលិកប្រចាំក្រសួងអប់រំ LBUSD បានធ្វើការទាក់ទងជាមួយក្រសួងផ្តល់ទីជំរក ដើម្បីបញ្ជាក់ថា សិស្ស ដែលគ្មានផ្ទះរស់នៅត្រឹមត្រូវ ពិតជាបានទទួលមែនអំពីជំនួយផ្នែកអាហារ សំលៀកបំពាក់ អ៊ិនធ័រណែត និង អ្វីចាំបាច់ជាបន្ថែមទៀត ។

## លើកបង្ហាញសេចក្តីរៀបរាប់នៃជំហាន ដែលបានចាត់ចែងដោយក្រសួង អ៊ិលអ៊ីអេ សំរាប់ផ្តល់បន្តជាជំនួយ ដែលមានគុណភាពខ្ពស់ ទៅកាន់សិស្សតាមរយៈរៀនពីចម្ងាយនៅតាមផ្ទះ ។

មិនខុសគ្នាពីការបង្ហាត់មេរៀននៅក្នុងថ្នាក់នោះទេ គឺក្រសួងអប់រំ LBUSD មានជំនឿថា កម្មវិធីរៀនពីចម្ងាយនៅតាមផ្ទះ ដែលមានគុណភាពខ្ពស់ គឺសំខាន់ចាំបាច់ណាស់សំរាប់ភាពជោគជ័យដល់សិស្ស ហើយយើងបានរៀបចំធ្វើតាមវិធីយ៉ាងសក្តិសិទ្ធ ។ នៅពេលសាលារៀនកំពុងបិទទ្វារ ក្រសួងអប់រំ ឌីស្រ្ទីគ បានប្រើជំនួយសំរាប់គាំទ្រទៅកាន់គ្រូបង្រៀនក្នុងគ្រាថ្មីមួយនេះ ។ ជំនួយបានផ្តល់តាមរយៈ អនឡាញ ដែលមានបុគ្គលិកនៅតាមក្រសួងថ្នាក់លើ និង គ្រូច្បងនៅតាមសាលារៀនជួយលើកបង្ហាញអំពីមធ្យោបាយត្រូវប្រើតាមសំរាប់ជួយសិស្សពីចម្ងាយៈ

- បង្កើតតាមរបៀប
- បង្កើតការរៀនអោយមានជាភាពសក្តិសិទ្ធ
- ទទួលយកជាយោបល់មកវិញ
- គិតគូរមុនគេទៅលើការរៀនតាមរយៈផ្នែកអារម្មណ៍ និង ផ្លូវចិត្ត
- ជួយទៅកាន់សិស្សទាំងអស់អោយបានទទួលឱកាសរៀនដូចតែគ្នា
- ផ្តល់ជំនួយគាំទ្រជាបន្តបន្ទាប់
- ចេះធ្វើទៅតាមការបត់បែន

ការិយាល័យថ្នាក់លើនិមួយៗបង្ហាញក្បួនណែនាំអំពីចំណុចទាំងឡាយណា ដែលសំខាន់មុនគេ និង ត្រូវទទួលការយកចិត្តទុកដាក់បង្ហាត់មុនគេរហូតទាល់តែដល់ពេលចុងបញ្ចប់ឆ្នាំសិក្សា ។ មេរៀនទាំងអស់នេះ គឺសំខាន់ណាស់សំរាប់ ភាពជោគជ័យដល់សិស្សក្នុងឆ្នាំសិក្សា 2020–2021 ។ គ្រូបង្រៀនមានឱកាសទទួលការហ្វឹកហ្វឺនតាមរយៈ អនឡាញ ពីគ្រូច្បង ឬ នាយកនៅតាមសាលារៀនរបស់ពួកគេរៀងៗខ្លួន ហើយទាំងគ្រូច្បង ទាំង

នាយក គឺធ្លាប់បាន ទទួលការហ្វឹកហ្វឺនខ្លួនគេផ្ទាល់ពីបុគ្គលិកនៅតាមកំរិតការិយាល័យថ្នាក់លើ ។ ឧទាហរណ៍: នៅថ្ងៃទី 24-25 ខែមិនា 2020 គឺមានគ្រូបង្រៀនចំនួនប្រហែល 325 នាក់បានចូលរួមទទួលការហ្វឹកហ្វឺន អនឡាញ អំពីរបៀបប្រើ Google Classroom និង មានចំនួន 410 នាក់ទៀតបានចំណាយពេលរៀនអំពីរបៀបប្រើ Google Meet សំរាប់ទាក់ទងជួបសិស្ស ។ ចំណេះជាច្រើនចំណែកនេះហើយ ដែលជួយបង្កើនការរៀនពីចម្ងាយនៅតាមផ្ទះ និង ស្របសេចក្តីត្រូវការរបស់សិស្សនៅតាមសាលារៀននិមួយៗ ។

យោងតាមការស្ទង់វាស់ពីបុគ្គល ដែលបានទទួលកម្មវិធីហ្វឹកហ្វឺនតាមរយៈ អនឡាញ គឺជំនួយគាំទ្រ ដែលពួកគេចង់បានច្រើនបំផុតសំរាប់ជួយទៅកាន់សិស្ស និង ក្រុមគ្រួសារ គឺការប្រើ បច្ចេកវិជ្ជា ដូចជា: Google Meet, Google Classroom និង Screencasting ។ មានចំនួនប្រហែល ពីរ ភាគ បី នៃអ្នកឆ្លើយបង្ហាញ បានបញ្ជាក់ថា ពួកគេមានភាពកក់ក្តៅល្មម ឬ ច្រើនអំពីការប្រើជំនួយ ។ ក្រៅពីការហ្វឹកហ្វឺន គឺគ្រូបង្រៀនបានទទួលក្បួនណែនាំតាម វិដេអូ និង អនឡាញ ដែលតាំងបង្ហាញជារៀងរាល់លើកក្នុង “Teacher Communication & Updates” web portal ។ ពួកគេក៏មានឱកាសផងដែរសំរាប់ជួបពិគ្រោះម្នាក់ទល់ម្នាក់ជាមួយគ្រូបង្រៀនដូចគ្នា ។

ក្រៅតែពីការផ្តល់ជំនួយទៅកាន់គ្រូបង្រៀន ក្រសួងអប់រំ LBUSD ក៏បានយកចិត្តទុកដាក់ផ្តល់ជាជំនួយបន្ថែមទៅកាន់សិស្ស និង ក្រុមគ្រួសារផងដែរ ។ ឧទាហរណ៍: មានបុគ្គលិកបានចំណាយពេលធ្វើការជាមួយមាតាបិតាដើម្បីណែនាំបង្ហាញពួកគាត់អំពីរបៀបខ្ចីប្រើ Chromebooks បើកចូលប្រើ Google Classroom និង អ្វីជាបន្ថែម ។ កម្មវិធីទទួលមើលសិស្ស បន្ទាប់ម៉ោងចេញរៀនពីថ្នាក់ ត្រូវបានធ្វើតាមរយៈ អនឡាញ ដើម្បីជួយសិស្សអំពីការបំពេញមេរៀន កម្មវិធីហាត់ប្រាណ និង ការអប់រំផ្លូវចិត្ត ។ អ្វីគួរសំគាល់ គឺក្រសួងអប់រំ LBUSD បានធ្វើការជាមួយ Schoolhouse.world ដែលជាអង្គការមិនយកកំរៃ ដើម្បីផ្តល់ជាមេរៀនសំរាប់ហាត់រៀនតាមនៅពេលណា និង នៅទីណាក៏បាន ។ ដោយប្រើស្របតាម Khan Academy គឺគ្រូបង្រៀនអាចបង្កើតជាកម្មវិធីរៀនជាមួយ ដែលមានគុណភាពខ្ពស់ សំរាប់ជួយសិស្សអំពីផ្នែកមេលេខ និង អ្វីផ្សេង ដែលប្រើតាមវិធីថ្មីសំរាប់ងាយយល់ ។ សិស្សអាចធ្វើការទាក់ទងជាមួយគ្រូបង្រៀនសំរាប់ទទួលយកជំនួយតាមសមត្ថភាពអាចរៀនទៅបាននៅពេលណាក៏បាន ។ ជំនួយនេះបានផ្តើមឡើងសំរាប់ជួយផ្នែកមេលេខជាកំរិតខ្ពស់មុនគេ ប៉ុន្តែ នឹងមានការពង្រីកទៅកាន់កំរិតថ្នាក់ផ្សេងៗទៀតជាបន្តបន្ទាប់ទៅ ។

លើកបង្ហាញសេចក្តីរៀបរាប់នៃជំហាន ដែលបានចាត់ចែងដោយក្រសួង អ៊ិលអ៊ីអេ សំរាប់ផ្តល់ជាជំនួយអាហារសាលារៀនទៅកាន់សិស្ស នៅពេលពួកគេកំពុងរៀនពីចម្ងាយនៅតាមផ្ទះ ។

នៅថ្ងៃដំបូង ដែលសាលារៀនបិទទ្វារភ្លាម គឺក្រសួងអប់រំ LBUSD បានចែកផ្តល់អាហារពេលព្រឹក/ថ្ងៃត្រង់យ៉ាងទៀងទាត់នៅតាមសាលារៀន 34 កន្លែង និង អាហារពេលល្ងាចបន្ថែមផងផ្តើមនៅថ្ងៃទី4 ខែឧសភា 2020 នៅតាមសាលារៀន 27 កន្លែង ។ មកដល់សព្វថ្ងៃនេះ ក្រសួងអប់រំ LBUSD បានចែកផ្តល់អាហារក្បែរចំនួន 12,000 ចំណែកក្នុងមួយថ្ងៃ ។ បើរាប់ទាំងអាហារពេលល្ងាចផង គឺមានលើសជាងចំនួន 18,000 ចំណែកក្នុងមួយថ្ងៃទូទាំងក្រសួងអប់រំ ឌីស្រ្ទីគ ទាំងមូល ។

អាហារទាំងអស់មានសំរាប់ចែកផ្តល់ពីម៉ោង 11:30 ព្រឹក ទៅ 12:30 រសៀល ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ និង ត្រូវបានធ្វើបន្តនៅក្នុងសប្តាហ៍សំរាកសំរាប់រដូវផ្ការីក ។ មាតាបិតាអាចទទួលយកអាហារបាន ដោយមិនបាច់នាំសិស្សទៅជាមួយ អោយតែពួកគាត់មានក្រដាសត្រឹមត្រូវសំរាប់បង្ហាញ ហើយអាចទៅទទួលយកនៅតាមសាលារៀនមួយណាក៏បាន ជាពិសេស នៅតាមសាលារៀន ដែលស្ថិតនៅក្នុងតំបន់ខ្វះខាតជាងគេ ។ បុគ្គលិក ដែលធ្វើការចែកផ្តល់អាហារ ត្រូវបានទទួលស្រោមដៃ គំរបមុខ និង អាកុល ជូតសំអាតដៃ ហើយពួកគេធ្វើការនៅឆ្ងាយពីគ្នា ។ នៅពេលទៅដល់សាលារៀន គឺមានការស្នើសុំអោយមាតាបិតាឈរឆ្ងាយពីគ្នា ពាក់គំរបមុខ និង ហាមមិនអោយទៅសាលារៀន បើសិនជាមានជម្ងឺ ។

លើកបង្ហាញសេចក្តីរៀបរាប់នៃជំហាន ដែលបានចាត់ចែងដោយក្រសួង អ៊ិលអ៊ីអេ សំរាប់ផ្តល់ជាជំនួយមើលខុសត្រូវទៅកាន់សិស្សក្នុងរយៈម៉ោងរៀនជាធម្មតា ។

ក្រសួងអប់រំ LBUSD រៀបចំជាកម្មវិធីទទួលផ្ញើក្មេងសំរាប់បុគ្គលិកប្រចាំ ឌីស្ត្រីគ ដើម្បីផ្តល់ឱកាសសំរាប់ពួកគេបន្តកិច្ចការចាំបាច់ប្រចាំថ្ងៃ ។ សិស្ស ដែលយកទៅដាក់ផ្ញើ គឺបានទទួលការមើលយ៉ាងត្រឹមត្រូវក្នុងរយៈម៉ោងរៀនជាធម្មតា ។ កម្មវិធីផ្ញើក្មេងត្រូវបានប្រើនៅតាម ប្រាំបី កន្លែង ក្នុងក្រសួងអប់រំ ឌីស្ត្រីគ ។ មានសិស្សប្រហែលចំនួន 150 នាក់ ពីអាយុ 0–14 ឆ្នាំ បានចុះឈ្មោះចូលរួមនៅតាមបន្ទប់រៀនប្រហែល 20 កន្លែង ។ សិស្សម្នាក់ៗបានទទួលប្រដាប់ប្រើសំរាប់បំពេញកិច្ចការរៀន និង កិច្ចការធ្វើសប្បាយក្រៅថ្នាក់ និង ក្នុងថ្នាក់ ។ ដើម្បីជួយសិស្សត្រឹមត្រូវតាមអាយុ គឺមេរៀន អនឡាញ ប្រចាំថ្ងៃត្រូវបានរៀបចំទទួល ។ មានការជំរុញអោយសិស្សនាំយកឡេប ថប ឬ ថាប្លិត របស់ខ្លួនមកពីផ្ទះ ប៉ុន្តែ បើសិនជាពួកគេគ្មានទេ គឺ Chromebooks នឹងមានសំរាប់ទុកអោយប្រើ ។

បុគ្គលិក ដែលមើលការខុសត្រូវ គឺធ្លាប់បានទទួលការហ្វឹកហ្វឺនអំពីរបៀបការពារសុខភាពរួចមកហើយ ។ នៅពេលនាំសិស្សមកទម្លាក់ និង ទទួលដកចេញទៅវិញ គឺមានការសុំអោយធ្វើពីចម្ងាយ ។ មានការស្ទង់វាស់កំដៅខ្លួន និង សញ្ញាផ្សេងៗ ហើយបើសិនជាមើលទៅឃើញថា ហួសកំរិត គឺហាមចូលកន្លែង ។ កិច្ចការធ្វើត្រូវបានរៀបដាក់ជាចំណែកឆ្ងាយៗពីគ្នា ។ គំរបមុខមានសំរាប់ចែកផ្តល់ ហើយការជូតសំអាតត្រូវបានធ្វើជារៀងរាល់លើក គ្រប់កន្លែង ។ នឹងមានការធ្វើបន្តជារបៀបនេះនៅតាមមណ្ឌល់ Child Development Centers នៅពេលចាប់ផ្តើមបើកទ្វារធ្វើការឡើងវិញនៅថ្ងៃទី15 ខែមិថុនា 2020 ដែលនឹងមានសិស្ស ព្រីស្គូល និង សិស្សអាយុតូចៗផ្សេងៗទៀតចំនួន 260 នាក់ចូលរួមនៅតាមចំនួន ដប់ កន្លែង ។

បន្ថែមទៅទៀត ក្រសួងអប់រំ LBUSD បានធ្វើសហការជាមួយ Pacific Gateway Workforce Partnership, Inc. ដែលជាអង្គការមិនយកកំរៃ ហើយស្ថិតនៅក្រោមសាខានៃអង្គការមួយផ្សេងទៀត ហៅ “WorkLB” ។ គំនិតបណ្តើមនៃសហការនេះ គឺសំដៅជួយបុគ្គលិកផ្នែកមើលខុសត្រូវកុមារ ដែលបានបាត់បង់ការងារមួយរយៈ អោយមានការងារធ្វើឡើងវិញ តាមការចែកផ្តល់ជំនួយទៅកាន់ក្រុមគ្រួសារ ។ ពួកគេធ្វើការទាក់ទងក្រុមគ្រួសារតាមរយៈ អនឡាញ សំរាប់តំរូវតាមសេចក្តីត្រូវការរៀងៗខ្លួន ។ សព្វថ្ងៃ យើងមានបុគ្គលិកប្រហែលចំនួន 300 នាក់ ដែលភាគច្រើន គឺធ្លាប់មានបទពិសោធរួចមកហើយពីក្រសួង Parks and Recreation Department, YMCA និង ក្រសួងផ្សេងៗទៀត ដែលមានមុខងារមើលខុសត្រូវយុវជន យុវនារី ។ ពួកគេទាំងអស់បានទទួលការពិនិត្យសុខភាពការពារជម្ងឺ កូវីដ-១៩ និង បានទទួលការហ្វឹកហ្វឺនអំពីរបៀបជួយសិស្សផ្នែក ហូមវើក និង កិច្ចការផ្សេងៗ ។ ក្រសួងអប់រំ LBUSD បានធ្វើការរាយផ្សាយអំពី WorkLB និង មធ្យោបាយ ដែលក្រសួងអប់រំអាចជួយបានអំពីកម្មវិធីមើលខុសត្រូវចំពោះសិស្សក្នុងរយៈម៉ោងរៀនជាធម្មតា ។

ក្រសួងអប់រំប្រចាំរដ្ឋ កាលីហ្វ័រញ៉ា
ខែឧសភា ឆ្នាំ2020